## Accepting direction



១ សុភ័ក្រ៖ វុទ្ធី! វុទ្ធីទំនេរអត់? ជួយលាងចានតិចបានអេ៎?
វុទ្ធី៖ បានតាស បង។ ចាននៅនោះមែន?
សុភ័ក្រ៖ ហ្នឹងហើយ។ លាងហើយ ជូតឲ្យស្ងួត ហើយជួយយកទៅទុកក្នុងទូនោះផងណា។
វុទ្ធី៖ បាទ។ បងទៅចុះ អត់អីទេ។ ខ្ញុំដឹងហើយ ចាំខ្ញុំរៀបទុកឲ្យ។

២ វុទ្ធី៖ បង មានអីឲ្យខ្ញុំជួយអេ៎?
សុភ័ក្រ៖ អ៊ូ វុទ្ធី កំពុងតែរកមុខ។ វុទ្ធី ជួយយកក្រដាសនេះទៅព្រីនផងបានអេ៎? យក ១០០ ច្បាប់។
វុទ្ធី៖ យក ១០០ ច្បាប់អ៊ំបង?
សុភ័ក្រ៖ ហ្នឹងហើយ សុំលឿនតិចណា។
វុទ្ធី៖ បាទ បង ប្រហែល ១៥ នាទីអីហើយៗ។

| | |
|---|---|
| សុភ័ក្រ | male or female Cambodian name |
| វុទ្ធី | male Cambodian name |
| អេ៎ | spoken form of ទេ |
| បានតាស | lit.: “can sure” = Sure, I can help! |
| ហ្នឹងហើយ | yeah, yes, correct |
| ណា | final particle to soften a statement or request |
| ទៅចុះ | You can go! |
| ចាំ[ខ្ញុំ] | phrase-initial: I will do ... |
| អ៊ូ | oh! |
| កំពុងតែរកមុខ | I was just looking you |
| ព្រីន | to print |
| អ៊ំ | particle used to form a yes/no question, similar to ឬ |
| ប្រហែល ... អី | about/approximately ... |
| ហើយៗ | to be ready |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

## Cultural notes

ចាស់ប្រើក្មេង ជារឿងធម្មតា ហើយការធ្វើតាមសំដីមនុស្សចាស់ជាសុជីវធម៌ ប៉ុន្តែពេលខ្លះ នៅពេលក្មេងនោះមិនចង់ធ្វើ គេធ្វើដែរតែដោយបញ្ចេញទឹកមុខមិនពេញចិត្ត។ ឃើញទឹកមុខបែបនោះ អ្នកប្រើអាចនឹងនិយាយថា “គ្រាន់តែប្រើប៉ុណ្ណឹងសោះ មុខឡើងក្រញូវ / មុខមើលមិនបាន”។

| | |
|---|---|
| ចាស់ប្រើក្មេង | the old use the young, i.e., the older generation customarily give orders to the younger generation |
| សុជីវធម៌ | good manners, good upbringing |
| មុខឡើងក្រញូវ | to make a sour face |
| មុខមើលមិនបាន | to make a sour face, lit.: [your] face can't be looked at [because the expression you wear on your face is too unpleasant] |

## Additional dialogue

សុភ័ក្រ៖ វុទ្ធី! វុទ្ធីមកជួយមើលកុំព្យូទ័រនេះតិចមើល។ ដូចចង់ខូចម៉េចទេ។ ម៉េចក៏ហ្វៃលនេះបើកអត់កើតអីចឹង?

វុទ្ធី៖ ឯណាបង? អ៊ំូ! ឥឡូវបងសាក ...

សុភ័ក្រ៖ មើល ឈប់សិន! ដំបូងចូលកន្លែងនេះ ត្រូវអេ៎? បន្ទាប់មក ចុចអានេះ ហើយ ... អ៊ំូ! បើកបានវិញហើយ។ អរគុណ វុទ្ធី។

វុទ្ធី៖ លើកក្រោយ បងឧស្សាហ៍អាប់ដេតកម្មវិធីហ្នឹងទៅ លែងអីហើយ។

សុភ័ក្រ៖ ហ្នឹងហើយ ចាំបងឧស្សាហ៍អាប់ដេតវា។

| | |
|---|---|
| ... តិចមើល | softens a command or request |
| ដូចចង់ ... ម៉េចទេ | it seems as if ... |
| ហ្វៃល | file |
| បើកអត់កើត | can't be opened, doesn't open |
| ឯណា? | what? |
| សាក | to try |
| អានេះ | equivalent to នេះ |
| លើកក្រោយ | next time |
| អាប់ដេត | to update |
| កម្មវិធី | software, program, app (on a computer or smartphone) |
| លែងអីហើយ | it will not be a problem again |
| ចាំ[បង] | phrase-initial: I will do ... |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.